ក្រសួងរ៉ែ និងថាមពល

Ministry of Mines and Energy

លេខ: ០១៧៩ រថ.នក.ប្រក


**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**Kingdom of Cambodia**

**Nation Religion King**

# ប្រកាស
# ស្តីពី
# បែបបទនិងនីតិវិធីនៃការធ្វើអធិការកិច្ចធនធានរ៉ែ សម្រាប់ការធ្វើអាជីវកម្មខ្សាច់ ក្រួស ឡាតេរីត ខ្សាច់បក និងអាចម៍ដី

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៩ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២៣ មាត្រា៣០ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ និងមាត្រា៤០ នៃច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញអនុក្រឹត្យលេខ ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសលេខ ០៣២០ រថ.អធរ.ប្រក ចុះថ្ងៃ២៥ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យចំណុះឱ្យនាយកដ្ឋាននានានៃអគ្គនាយកដ្ឋានធនធានរ៉ែ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល


លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ ( ៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ ( ៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ ( ៨៥៥) ២៣ ២១៩ ៥៨៤

#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១ ._**

ប្រកាសនេះមានគោលបំណងកំណត់អំពីបែបបទនិងនីតិវិធី សម្រាប់ការធ្វើអធិការកិច្ចធនធានរ៉ែ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២ ._**

ប្រកាសនេះមានគោលដៅកំណត់អំពី បែបបទនិងនីតិវិធីនៃការធ្វើអធិការកិច្ច និងវិធានការច្បាប់ដោយបញ្ជាក់អំពីអង្គភាពមានសមត្ថកិច្ច សិទ្ធិរបស់ក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ច សិទ្ធិនិងកាតព្វកិច្ចរបស់សម្បទានិកពាក់ព័ន្ធនឹងការងារអធិការកិច្ច ដើម្បីជំរុញការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធភាព អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ និងច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២៣ មាត្រា៣០ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ និងមាត្រា៤០ នៃច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ និងបទប្បញ្ញត្តិពាក់ព័ន្ធនានាជាធរមាន។

**ប្រការ៣ ._**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះការធ្វើអធិការកិច្ច លើរាល់ប្រតិបត្តិការធនធានរ៉ែ (ខ្សាច់ ក្រួស ឡាតេរីត ខ្សាច់បក និងអាចម៍ដី) ទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤ ._**

ក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ច សំដៅដល់ក្រុមការងារដែលត្រូវបានចាត់តាំងដោយរដ្ឋមន្ត្រី មានភារកិច្ចត្រួតពិនិត្យនិងធ្វើអធិការកិច្ចលើប្រតិបត្តិការធនធានរ៉ែ។

មន្ត្រីអធិការកិច្ចធនធានរ៉ែ សំដៅដល់សមាជិកក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ច ដែលមានភារកិច្ចត្រួតពិនិត្យលើបទល្មើសប្រតិបត្តិការធនធានរ៉ែ នៃក្រសួងរ៉ែនិងថាមពល និងឬមន្ទីររ៉ែ/និងថាមពល រាជធានី ខេត្ត ដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ស្របតាមមាត្រា២៣ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២៣ មាត្រា៣០ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ និងមាត្រា៤០ នៃច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ។

## ជំពូកទី២
## សិទ្ធិក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ច

**ប្រការ៥ ._**

ក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ច មានសិទ្ធិដូចខាងក្រោម ៖

- ធ្វើការតាមដាននិងពិនិត្យដើម្បីបញ្ជាក់ពីការអនុវត្តបទប្បញ្ញត្តិទាំងអស់នៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ និងច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២៣ មាត្រា៣០

មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ និងមាត្រា៤០ នៃច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ

- ផ្អាកប្រតិបត្តិការធនធានរ៉ែជាបណ្តោះអាសន្ន ក្នុងករណីដែលប្រតិបត្តិការធនធានរ៉ែនោះ អាចបង្កគ្រោះថ្នាក់ ឬហានិភ័យធ្ងន់ធ្ងរដល់សុវត្ថិភាពការងារ បរិស្ថាន និងសង្គម
- ធ្វើអធិការកិច្ចលើគ្រប់ប្រតិបត្តិការធនធានរ៉ែដែលគ្មានការអនុញ្ញាត ឬការដ្ឋាននិងអណ្តូងរ៉ែដែលបោះបង់
- ផ្អាកសកម្មភាព ឬឃាត់ទុកមធ្យោបាយបម្រើឱ្យប្រតិបត្តិការធនធានរ៉ែ ល្មើសច្បាប់ ឬមិនត្រឹមត្រូវតាមគោលការណ៍បច្ចេកទេស ដោយផ្អែកតាមនីតិវិធីច្បាប់ជាធរមាន
- ធ្វើអធិការកិច្ចក្នុងដែនអាជ្ញាបណ្ណនិងតំបន់ពាក់ព័ន្ធ ដើម្បីកំណត់វាយតម្លៃអំពីស្ថានភាពប្រតិបត្តិការធនធានរ៉ែ និងពិនិត្យអនុលោមភាពតាមច្បាប់ គោលការណ៍បច្ចេកទេស និងបទប្បញ្ញត្តិស្តីពីសុវត្ថិភាពនិងការការពារបរិស្ថាននិងសង្គម
- តាមដានការកែតម្រូវរបស់សម្បទានិក ស្របតាមការកំណត់របស់ក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ច
- តម្រូវឱ្យសម្បទានិកផ្តល់ព័ត៌មាននិងឯកសារផ្សេងៗ ដែលពាក់ព័ន្ធក្នុងប្រតិបត្តិការធនធានរ៉ែ
- តម្រូវឱ្យសម្បទានិកបញ្ឈប់ប្រតិបត្តិការធនធានរ៉ែផ្នែកណាមួយ ឬក្នុងការដ្ឋានទាំងមូល និង/ឬជម្លៀសបុគ្គលិកកម្មករចេញពីការដ្ឋាន ឬផ្នែកណាមួយដែលមន្ត្រីអធិការកិច្ចពិនិត្យឃើញថាជាការចាំបាច់ដើម្បីធានាសុវត្ថិភាព សុខភាព និងបរិស្ថាន។
- ត្រួតពិនិត្យការអនុវត្តបទបញ្ជាឱ្យបានត្រឹមត្រូវលើសុខភាពនិងសុវត្ថិភាពរបស់កម្មករនិយោជិតនិងសាធារណជនទូទៅ និងការការពារបរិស្ថាន និង
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់រដ្ឋមន្ត្រី។

**ប្រការ៦ ..**

មន្ត្រីអធិការកិច្ចធនធានរ៉ែ ដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ មកពីអគ្គនាយកដ្ឋានធនធានរ៉ែនិងនាយកដ្ឋាននីតិកម្ម មានសមត្ថកិច្ចក្នុងការស្រាវជ្រាវនិងត្រួតពិនិត្យបទល្មើសក្នុងប្រតិបត្តិការធនធានរ៉ែនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

មន្ត្រីអធិការកិច្ចធនធានរ៉ែ ដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ មកពីមន្ទីររ៉ែនិងថាមពលរាជធានីខេត្ត មានសមត្ថកិច្ចក្នុងការស្រាវជ្រាវនិងត្រួតពិនិត្យបទល្មើសក្នុងប្រតិបត្តិការធនធានរ៉ែនៅក្នុងដែនដីសាមី ។

**ប្រការ៧ ..**

មន្ត្រីអធិការកិច្ចធនធានរ៉ែ អាចធ្វើការឆែកឆេរទីតាំងដែលជាកម្មសិទ្ធិសាធារណៈ ឬកម្មសិទ្ធិឯកជនមានលក្ខណៈបើកចំហដោយពុំមានការហ៊ុំព័ទ្ធជិត ដែលអាចមើលឃើញ ឬមានស្លាកស្នាមឬតម្រុយច្បាស់លាស់ អំពើល្មើសលើប្រតិបត្តិការធនធានរ៉ែជាក់ស្តែង ប៉ុន្តែត្រូវគោរពតាមវិធានការដូចខាងក្រោម៖

- ត្រូវទទួលជាបឋមនូវការអនុញ្ញាតពីព្រះរាជអាជ្ញា ទោះបីជាការអនុញ្ញាតដោយផ្ទាល់មាត់ក៏ដោយ។ ក្នុងករណីចាំបាច់ត្រូវមានវត្តមានរបស់ព្រះរាជអាជ្ញាដើម្បីដឹកនាំនីតិវិធី និងត្រូវមានអាជ្ញាធរមូលដ្ឋាននៅកន្លែងកើតហេតុ ឬកម្លាំងប្រដាប់អាវុធចូលរួមតាមការចាំបាច់ក្នុងប្រតិបត្តិការឆែកឆេរ
- កត់ត្រានិងរក្សាទុកជាបណ្ដោះអាសន្ននូវវត្ថុតាងនិងភស្តុតាងផ្សេងទៀតនៅកន្លែងកើតហេតុ ឬដកយកសំណាករ៉ែនិងសារធាតុគីមីប្រើប្រាស់ក្នុងការដ្ឋានរ៉ែ ក្នុងករណីដែលមានការប្រើប្រាស់ដើម្បីវិភាគ
- បំពេញសំណុំបែបបទដែលពាក់ព័ន្ធនឹងបទល្មើសនៅនឹងកន្លែងកើតហេតុឱ្យបានគ្រប់គ្រាន់តាមនីតិវិធី និង
- ក្នុងករណីមានការឃាត់ខ្លួនជនសង្ស័យ ការនាំខ្លួន និងបញ្ជូនសំណុំឯកសារឃាត់ខ្លួនជនសង្ស័យត្រូវប្រគល់ជូនព្រះរាជអាជ្ញាក្នុងដែនសមត្ថកិច្ចសាមី ដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ។

## ជំពូកទី៣
## សិទ្ធិនិងកាតព្វកិច្ចរបស់សម្បទានិកក្នុងប្រតិបត្តិការអធិការកិច្ច

### ប្រការ៨ ..

សម្បទានិកឬអ្នកគ្រប់គ្រងតំបន់ប្រតិបត្តិការធនធានរ៉ែ មានសិទ្ធិនិងកាតព្វកិច្ចដូចខាងក្រោម៖

- ស្នើសុំឱ្យក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ច បង្ហាញលិខិតបញ្ជាបេសកកម្មនិងកត់ត្រានូវរាល់សកម្មភាពនៃការធ្វើប្រតិបត្តិការធនធានរ៉ែរបស់ខ្លួន នៅក្នុងកំណត់ហេតុត្រួតពិនិត្យនិងទទួលបាននូវកំណត់ហេតុថតចម្លងនៃការធ្វើអធិការកិច្ច
- ស្នើសុំមិនឱ្យបញ្ចេញឬផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានសម្ងាត់ដែលពាក់ព័ន្ធនឹងប្រតិបត្តិការធនធានរ៉ែរបស់ខ្លួន
- ត្រូវអនុញ្ញាតឱ្យក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ច ចូលត្រួតពិនិត្យនិងផ្ដល់កិច្ចសហការក្នុងការធ្វើអធិការកិច្ចក្នុងទីតាំងរបស់ខ្លួន ដូចមានចែងនៅក្នុងច្បាប់ស្ដីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ និងច្បាប់ស្ដីពីវិសោធនកម្មមាត្រា៣ មាត្រា២៣ មាត្រា៣០ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ និងមាត្រា៤០ នៃច្បាប់ស្ដីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀតជាធរមាន
- ត្រូវឆ្លើយតបនឹងបញ្ជីសំណួរ ពន្យល់ ផ្ដល់ព័ត៌មាន និងឯកសារផ្សេងៗពាក់ព័ន្ធនឹងការធ្វើប្រតិបត្តិការធនធានរ៉ែរបស់ខ្លួន តាមការស្នើសុំរបស់ក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ច និង
- ត្រូវបំពេញកាតព្វកិច្ចផ្សេងទៀត ដើម្បីសម្រួលដល់ការធ្វើអធិការកិច្ច។

**ប្រការ៩ ..**

ក្នុងករណីរកឃើញថាសម្បទានិកប្រព្រឹត្តល្មើស រាល់ការចំណាយក្នុងការលើកដាក់ ការដឹកជញ្ជូន ការថែរក្សា និងការបំផ្លាញចោលនូវវត្ថុតាងល្មើសពាក់ព័ន្ធនឹងប្រតិបត្តិការធនធានរ៉ែជាបន្ទុករបស់សម្បទានិក។

ក្នុងករណីដែលសម្បទានិកមិនព្រមចេញថ្លៃចំណាយដូចមានចែងក្នុងកថាខណ្ឌទី១ នោះបន្ទុកចំណាយជាបន្ទុករបស់រដ្ឋ។ បន្ទុកចំណាយដែលសម្បទានិកមិនព្រមចេញនេះនឹងត្រូវបូកបញ្ចូលទៅក្នុងការផាកពិន័យសរុបដោយក្រសួងរ៉ែនិងថាមពល។

ក្នុងករណីពុំមានអ្នកទទួលខុសត្រូវនៅនឹងកន្លែងប្រព្រឹត្តបទល្មើស នោះរាល់ការចំណាយក្នុងការលើកដាក់ ការដឹកជញ្ជូន ការថែរក្សា និងការបំផ្លាញចោល វត្ថុតាងល្មើសពាក់ព័ន្ធនឹងប្រតិបត្តិការធនធានរ៉ែជាបន្ទុករបស់រដ្ឋ។

## ជំពូកទី៤
## នីតិវិធីអធិការកិច្ចធនធានរ៉ែ

**ប្រការ១០ ..**

ក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ចមានសិទ្ធិធ្វើអធិការកិច្ចតាមកាលកំណត់ ឬមិនតាមកាលកំណត់ ដោយមានការជូនដំណឹងជាមុន ឬដោយពុំមានការជូនដំណឹងជាមុន ដល់សម្បទានិក។

ក្នុងករណីធ្វើអធិការកិច្ចដោយមានការជូនដំណឹងជាមុន សេចក្តីជូនដំណឹងផ្លូវការត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវចុះហត្ថលេខាដោយប្រធានស្ថាប័ន។ សេចក្តីជូនដំណឹងផ្លូវការនេះត្រូវធ្វើជូនសម្បទានិក ឬអាចផ្តល់ព័ត៌មានជាមុនដោយផ្ទាល់មាត់ក្នុងរយៈពេលមិនតិចជាង១ (មួយ) ថ្ងៃ មុនថ្ងៃធ្វើអធិការកិច្ច។

ការធ្វើអធិការកិច្ចដោយពុំមានការជូនដំណឹងជាមុនត្រូវអនុវត្តចំពោះសកម្មភាពណាមួយដូចខាងក្រោម៖

- ករណីស្រាវជ្រាវឃើញបទល្មើសជាក់ស្តែងពាក់ព័ន្ធនឹងប្រតិបត្តិការធនធានរ៉ែ
- ករណីអធិការកិច្ចដែលត្រូវឆ្លើយតបចំពោះបណ្តឹង ឬការធ្វើអធិការកិច្ចចំពោះគ្រោះថ្នាក់ជាយថាហេតុណាមួយ ដែលបង្កឡើងដោយឧបទ្ទវហេតុណាមួយ ពាក់ព័ន្ធនឹងប្រតិបត្តិការធនធានរ៉ែ
- ករណីចុះបង្ក្រាបប្រតិបត្តិការធនធានរ៉ែដែលគ្មានអាជ្ញាបណ្ណ និង
- ករណីការធ្វើអធិការកិច្ចសារជាថ្មី ដើម្បីត្រួតពិនិត្យនិងធានានូវការអនុវត្តតាមវិធានការនានា ឬការដាក់ទណ្ឌកម្មផ្សេងទៀតដែលក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ច បានដាក់ចេញនៅពេលធ្វើអធិការកិច្ចលើកមុន។

គំរូសេចក្តីជូនដំណឹងស្តីពីការធ្វើអធិការកិច្ចធនធានរ៉ែត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី១នៃប្រកាសនេះ។

**ប្រការ១១ ..**

ក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ចដែលត្រូវចុះធ្វើអធិការកិច្ចដូចមានចែងក្នុងប្រការ៦ ខាងលើត្រូវមានលិខិតបញ្ជាបេសកកម្មនិងប័ណ្ណសម្គាល់ខ្លួន ដោយឡែកចំពោះមន្ត្រីអធិការកិច្ចធនធានរ៉ែត្រូវ

ស្លៀកពាក់ឯកសណ្ឋាន។

**ប្រការ១២.-**

នៅក្នុងពេលធ្វើអធិការកិច្ច ក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ចត្រូវអនុវត្តនីតិវិធីតាមដំណាក់កាលដូចខាងក្រោម៖

**<u>១- ដំណាក់កាលត្រៀមអធិការកិច្ច</u>**

នៅមុនពេលចុះធ្វើអធិការកិច្ច ក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ចត្រូវ៖

- ស្នើសុំលិខិតបញ្ជាបេសកកម្ម
- ជូនដំណឹងដល់សម្បទានិកនៅក្នុងគោលដៅបេសកកម្ម ក្នុងករណីការធ្វើអធិការកិច្ចដោយមានការជូនដំណឹងជាមុន។

ក្នុងករណីចាំបាច់ ក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ច អាចស្នើសុំកិច្ចសហការជាមួយនឹងក្រសួងស្ថាប័នពាក់ព័ន្ធ និង/ឬ អាជ្ញាធរដែនដីដែលត្រូវចុះធ្វើអធិការកិច្ច។

**<u>២- ដំណាក់កាលមុនត្រួតពិនិត្យ</u>**

នៅពេលចូលដល់ទីតាំងដែលត្រូវធ្វើការត្រួតពិនិត្យដូចជា ការដ្ឋានរ៉ែ ឬទីកន្លែងដែលកើតមានបទល្មើស ឬមានគ្រោះថ្នាក់ជាយថាហេតុណាមួយ ដែលពាក់ព័ន្ធនឹងប្រតិបត្តិការធនធានរ៉ែ ក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ចត្រូវ៖

- បង្ហាញលិខិតបញ្ជាបេសកកម្មនិងសួររកម្ចាស់ការដ្ឋាន ឬអ្នកតំណាង ឬអ្នកទទួលខុសត្រូវក្នុងទីតាំងដែលត្រូវត្រួតពិនិត្យ និង
- ពន្យល់ដល់ម្ចាស់ការដ្ឋាន ឬអ្នកតំណាង ឬអ្នកទទួលខុសត្រូវអំពីគោលបំណងនៃការធ្វើអធិការកិច្ចរបស់ខ្លួន ស្របតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតជាធរមាន។

ខ្លឹមសារនៃសេចក្តីពន្យល់អំពីគោលបំណងនៃការធ្វើអធិការកិច្ចធនធានរ៉ែត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

**<u>៣- ដំណាក់កាលត្រួតពិនិត្យ</u>**

ក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ចត្រូវ ៖

- ឱ្យម្ចាស់ការដ្ឋាន ឬអ្នកតំណាង ឬអ្នកទទួលខុសត្រូវក្នុងទីតាំងប្រតិបត្តិការធនធានរ៉ែ បង្ហាញអាជ្ញាបណ្ណ ឬប្រកាសស្តីពីលក្ខខណ្ឌអាជ្ញាបណ្ណ ឬឯកសារពាក់ព័ន្ធផ្សេងៗ តាមការចាំបាច់
- ត្រួតពិនិត្យប្រតិបត្តិការធនធានរ៉ែ និងអនុលោមភាពតាមច្បាប់និងលិខិតបទដ្ឋានជាធរមាន
- ធ្វើកំណត់ហេតុបឋមមួយ មុននឹងចាកចេញពីការដ្ឋានឬទីតាំងត្រួតពិនិត្យ ក្នុងករណីក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ចត្រូវចាកចេញដោយមិនទាន់បានបញ្ចប់ការត្រួតពិនិត្យទាំងស្រុងនិង
- ចាត់វិធានការនានាស្របតាមបញ្ញត្តិនៃប្រកាសនេះ ក្នុងករណីពិនិត្យឃើញមានកំហុស។

**<u>៤- ដំណាក់កាលបញ្ចប់ការត្រួតពិនិត្យការដ្ឋាននីមួយៗ</u>**

នៅពេលបញ្ចប់ការត្រួតពិនិត្យការដ្ឋាននីមួយៗ ក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ចត្រូវ៖

- ធ្វើកំណត់ហេតុបូកសរុបបញ្ចប់ការត្រួតពិនិត្យការដ្ឋាននោះ
- ត្រូវអានកំណត់ហេតុនោះ ឱ្យដល់ម្ចាស់ការដ្ឋានឬអ្នកតំណាងឬអ្នកទទួលខុសត្រូវ ក្នុងទីតាំង ឬតម្រូវឱ្យបុគ្គលនោះអានដោយផ្ទាល់ដើម្បីយល់ព្រមផ្តិតស្នាមម្រាមដៃលើកំណត់ហេតុនោះ។ ក្នុងករណីដែលម្ចាស់ការដ្ឋានឬអ្នកតំណាង ឬអ្នកទទួលខុសត្រូវក្នុងទីតាំងមិនយល់ព្រមផ្តិតស្នាមម្រាមដៃលើកំណត់ហេតុនោះទេ ត្រូវចុះក្នុងកំណត់ហេតុអំពីមូលហេតុមិនយល់ព្រម និងត្រូវរាយការណ៍ជូនប្រធានស្ថាប័នដើម្បីចាត់វិធានការសមស្របបន្ថែម ដូចមានចែងក្នុងបញ្ញត្តិនៃប្រកាសនេះ។

ទម្រង់កំណត់ហេតុត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៣ (ចំណុចក) នៃប្រកាសនេះ។

<u>៥- ដំណាក់កាលក្រោយពេលបញ្ចប់អធិការកិច្ច</u>

ក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ច ត្រូវធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរ ជូនប្រធានស្ថាប័ន ក្នុងរយៈពេលយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ ដោយគិតចាប់ពីថ្ងៃបញ្ចប់ការងារអធិការកិច្ចធនធានរ៉ែ។ ក្នុងករណីចាំបាច់ ក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ច អាចរាយការណ៍ដោយផ្ទាល់មាត់ជាមុនដល់ប្រធានស្ថាប័ន។

របាយការណ៍អធិការកិច្ចធនធានរ៉ែ ត្រូវមានខ្លឹមសារសំខាន់ៗ ដូចខាងក្រោម៖

- សមាសភាពក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ច និងអ្នកពាក់ព័ន្ធផ្សេងៗទៀត
- គោលបំណងនៃការធ្វើអធិការកិច្ច
- ទីកន្លែងធ្វើអធិការកិច្ច
- លទ្ធផលនៃការធ្វើអធិការកិច្ច
- វិធានការរបស់ក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ច នៅតាមទីតាំងត្រួតពិនិត្យនីមួយៗ
- ការស្នើសុំវិធានការបន្ត ឬសេចក្តីសម្រេចពីប្រធានស្ថាប័ន និង
- ត្រូវភ្ជាប់ឯកសារពាក់ព័ន្ធ ដូចជារូបថតសកម្មភាព ឬភស្តុតាងផ្សេងទៀតជាចាំបាច់។

## ប្រការ១៣ ..

រាល់ប្រតិបត្តិការរបស់ក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ច ត្រូវអនុវត្តតាមបទប្បញ្ញត្តិច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ និងច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២៣ មាត្រា៣០ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ និងមាត្រា៤០ នៃច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ នីតិវិធីនៃប្រកាសនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀតជាធរមាន។

ក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ចអាចស្នើសុំជំនួយពីអាជ្ញាធរដែនដីនិងកងកម្លាំងឬអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមពិនិត្យនិងបង្ក្រាបបទល្មើសធនធានរ៉ែដូចមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ និងច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២៣ មាត្រា៣០

មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ និងមាត្រា៤០នៃច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀតជាធរមាន។

**ប្រការ១៤ ..**

ក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ច មានសិទ្ធិចេញលិខិតឱ្យកែតម្រូវឬលិខិតព្រមានដល់សម្បទានិក។ លិខិតឱ្យកែតម្រូវអនុវត្ត ចំពោះករណីពិនិត្យឃើញថាអាចមានហានិភ័យគ្រោះថ្នាក់ជាយថាហេតុ។ លិខិតព្រមានអនុវត្ត ចំពោះកំហុសពាក់ព័ន្ធនឹងបទដ្ឋានបច្ចេកទេស ឬលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។

រាល់ការកែតម្រូវ ត្រូវបញ្ជាក់អំពីកម្មវត្ថុ មូលហេតុ និងឱសានវាទនៃការតម្រូវនោះ។ រាល់ការព្រមានត្រូវបញ្ជាក់អំពីកំហុសរបស់សម្បទានិក និងកំណត់ឱសានវាទឱ្យបានច្បាស់លាស់។ ការកែតម្រូវឬការព្រមាន ត្រូវចុះក្នុងកំណត់ហេតុត្រួតពិនិត្យ ដើម្បីតាមដានការកែតម្រូវរបស់សម្បទានិកនៅពេលក្រោយ។

គំរូលិខិតឱ្យកែតម្រូវឬលិខិតព្រមានស្តីពីការធ្វើអធិការកិច្ចធនធានរ៉ែ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៣ (ចំណុចខនិងចំណុចគ) នៃប្រកាសនេះ។

**ប្រការ១៥ ..**

ក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ច មានសិទ្ធិផាកពិន័យលើបុគ្គលប្រព្រឹត្តល្មើស ដូចមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ ច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២៣ មាត្រា៣០ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ និងមាត្រា៤០ នៃច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ និងប្រកាសស្តីពីនីតិវិធីនៃការផាកពិន័យបទល្មើសក្នុងប្រតិបត្តិការធនធានរ៉ែក្រោមអាជ្ញាបណ្ណរ៉ែខ្សាច់ ក្រួស ឡាតេរីត ខ្សាច់បក និងអាចម៍ដី។

ក្នុងករណីនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែល ក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ចត្រូវរាយការណ៍ទៅប្រធានស្ថាប័ន ដើម្បីស្នើសុំចាត់វិធានការស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ១៦ ..**

នៅពេលធ្វើអធិការកិច្ចធនធានរ៉ែ ក្នុងករណីរកឃើញកំហុស ក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ចមានសិទ្ធិផ្អាកផ្នែកណាមួយដែលពាក់ព័ន្ធនឹងកំហុសនោះ ឬផ្អាកទាំងស្រុងនៃប្រតិបត្តិការធនធានរ៉ែជាបណ្តោះអាសន្ន ថតចម្លងឯកសារពាក់ព័ន្ធប្រតិបត្តិការធនធានរ៉ែ ចាប់យកវត្ថុតាងនិងបិទស្លាកបោះត្រាលើវត្ថុតាង និងចាត់វិធានការតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀតជាធរមាន។

ក្នុងករណីពិនិត្យឃើញវត្ថុតាងដែលអាចត្រៀមប្រព្រឹត្តបទល្មើស មន្ត្រីអធិការកិច្ចធនធានរ៉ែ មានសិទ្ធិចាប់យកវត្ថុតាងនិងបិទស្លាកបោះត្រាលើវត្ថុតាង និងចាត់វិធានការតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀតជាធរមាន ។

គំរូសេចក្តីសម្រេចផ្អាកផ្នែកណាមួយឬទាំងស្រុងស្តីពីការធ្វើអធិការកិច្ចធនធានរ៉ែ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៤ នៃប្រកាសនេះ។

**ប្រការ១៧ ..**

ដោយមានការអនុញ្ញាតពីអយ្យការអមសាលាដំបូងរាជធានី ខេត្តសាមី មន្ត្រីអធិការកិច្ចធនធានរ៉ែ អាចចាប់យកវត្ថុតាងឬសារធាតុហាមឃាត់ដែលបង្កគ្រោះថ្នាក់ដល់សុខភាពមនុស្ស សត្វនិងបរិស្ថាន ដែលពាក់ព័ន្ធនឹងបទល្មើសពាក់ព័ន្ធនឹងប្រតិបត្តិការធនធានរ៉ែ ដើម្បីធ្វើការបំផ្លាញចោល។

វត្ថុតាងឬភស្តុតាងនៃបទល្មើសដែលត្រូវចាប់យក ក្នុងពេលធ្វើអធិការកិច្ចត្រូវរក្សាទុកនៅទីកន្លែងដែលមានសន្តិសុខនិងសុវត្ថិភាពត្រូវបិទស្លាកបោះត្រាឬគូសខ្សែងសម្គាល់ សោរទ្វារឃ្លាំងសម្រាប់រក្សាវត្ថុតាងឬភស្តុតាងដែលហាមឃាត់ការប៉ះពាល់ រហូតដល់ដោះស្រាយចប់តាមនីតិវិធីជាធរមាន។ ក្នុងករណីអត្តសញ្ញាណម្ចាស់វត្ថុតាងនៃបទល្មើសដែលត្រូវរឹបអូសមករក្សាទុកបណ្ដោះអាសន្នមិនត្រូវបានស្គាល់ ក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ចឬមន្ត្រីអធិការកិច្ចធនធានរ៉ែត្រូវចេញសេចក្តីជូនដំណឹងរកជនល្មើសឬម្ចាស់វត្ថុតាងនៃបទល្មើស ដើម្បីចូលខ្លួនមកដោះស្រាយតាមនីតិវិធីជាធរមាន ក្នុងរយៈពេលមិនលើសពី៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃធ្វើអធិការកិច្ចនិងចាប់យកវត្ថុតាងនោះ។ ក្នុងករណីម្ចាស់វត្ថុតាងឬភស្តុតាងមិនចូលមកដោះស្រាយក្នុងពេល៣០ (សាមសិប) ថ្ងៃនេះទេ វត្ថុតាងដែលត្រូវបានចាប់យកនេះត្រូវចាត់ទុកជាសម្បត្តិរដ្ឋ។

គំរូសេចក្តីជូនដំណឹងស្តីពីការឃាត់ទុកវត្ថុតាងឬភស្តុតាងត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៥នៃប្រកាសនេះ។ សេចក្តីជូនដំណឹងនេះ ត្រូវបិទផ្សាយនៅឃុំ-សង្កាត់ និង/ឬទីតាំងដែលវត្ថុតាងឬភស្តុតាងត្រូវបានឃាត់ទុក។

**ប្រការ១៨ ..**

សម្បទានិកអាចធ្វើបណ្តឹងតវ៉ាមករដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលដើម្បីពិនិត្យនិងសម្រេច ក្នុងរយៈពេល ១០ (ដប់) ថ្ងៃ គិតចាប់ពីថ្ងៃចេញវិធានការ ក្នុងករណីមិនសុខចិត្តចំពោះវិធានការណាមួយ របស់ក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ច។

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល ត្រូវចេញសេចក្តីសម្រេចលើបណ្តឹងតវ៉ានោះ ក្នុងរយៈពេល៤៥ (សែសិបប្រាំ) ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលបណ្តឹង។

**ប្រការ១៩ ..**

ក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ចត្រូវធ្វើបញ្ជីត្រួតពិនិត្យអនុលោមភាព សម្រាប់ប្រភេទការដ្ឋានរ៉ែនីមួយៗ និងកំណត់វិធានការក្នុងករណីពិនិត្យឃើញកំហុសរបស់សម្បទានិក លើចំណុចណាមួយក្នុងបញ្ជីត្រួតពិនិត្យទាំងនោះ។

**ប្រការ២០ ..**

ក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ចត្រូវគ្រប់គ្រងឯកសារនៃករណីសំណុំរឿងបទល្មើសនីមួយៗ ដោយត្រូវរៀបចំនិងកត់ត្រានៅក្នុងសៀវភៅកំណត់ត្រាតាមដានករណីបទល្មើស ដែលជាឯកសារមូលដ្ឋានប្រើប្រាស់សម្រាប់គ្រប់គ្រងការងារធ្វើអធិការកិច្ចនិងការអនុវត្តច្បាប់ ដោយត្រូវកត់ត្រានូវព័ត៌មាននិងទិន្នន័យ

សំខាន់ៗ តាមករណីបទល្មើសនីមួយៗ ចាប់ពីដំណាក់កាលធ្វើអធិការកិច្ចលើកដំបូង រហូតដល់ករណីបទល្មើសនីមួយៗ ត្រូវបានដោះស្រាយរួចជាស្ថាពរតាមនីតិវិធី។

សំណុំឯកសារពាក់ព័ន្ធនឹងការធ្វើអធិការកិច្ចត្រូវរក្សាទុកនៅនាយកដ្ឋានត្រួតពិនិត្យប្រតិបត្តិការធនធានរ៉ែ នៃអគ្គនាយកដ្ឋានធនធានរ៉ែ។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**ប្រការ២១ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ២២ ..**

នាយកខុទ្ទកាល័យ អគ្គាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានរ៉ែ ប្រធាននាយកដ្ឋាន ប្រធានមន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃពុធ ៨ កើត ខែ ពិសាខ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

ស៊ុយ សែម

**កន្លែងទទួល** :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ២២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធទី១ ស្តីពី "សេចក្តីជូនដំណឹងស្តីពីការធ្វើអធិការកិច្ចធនធានរ៉ែ" នៃ ប្រកាសស្តីពីបែបបទនិងនីតិវិធីនៃការធ្វើអធិការកិច្ចធនធានរ៉ែ សម្រាប់ការធ្វើអាជីវកម្មខ្សាច់ ក្រួស ឡាតេរីត ខ្សាច់បក និងអាចម៍ដី**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមការងារត្រួតពិនិត្យនិង**
**ធ្វើអធិការកិច្ច ក្រុមទី........./**
**មន្ទីររ៉ែនិងថាមពល...............................**

# សេចក្តីជូនដំណឹង
# ស្តីពីការធ្វើអធិការកិច្ចធនធានរ៉ែ

## ក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ចក្រុមទី......../
## មន្ទីររ៉ែនិងថាមពល.................................

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៩ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២៣ មាត្រា៣០ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ និងមាត្រា៤០ នៃច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញប្រកាសលេខ................ប្រក. ចុះថ្ងៃទី......... ខែ............. ឆ្នាំ.................... ស្តីពីបែបបទនិងនីតិវិធីនៃការធ្វើអធិការកិច្ចធនធានរ៉ែ សម្រាប់ការធ្វើអាជីវកម្មខ្សាច់ ក្រួស ឡាតេរីត ខ្សាច់បក និងអាចម៍ដី
  ប្រកាសលេខ.............................. ចុះថ្ងៃទី.......... ខែ.............. ឆ្នាំ.................. ស្តីពីលក្ខខណ្ឌនៃអាជ្ញាបណ្ណ
  .........................................................................................................................................

## ជម្រាបមក

លោក/លោកស្រី......................................................... ឋានៈ............................................. នៃក្រុមហ៊ុន
.......................................................................................................................................................................
មេត្តាជ្រាបថាដោយអនុលោមតាមលិខិតបញ្ជាបេសកកម្មលេខ..................................លបប ចុះថ្ងៃទី..................... ខែ..................... ឆ្នាំ.................. ក្រសួងរ៉ែនិងថាមពលបានចាត់តាំងមន្ត្រីអធិការកិច្ចធនធានរ៉ែមានសមត្ថកិច្ចដើម្បីត្រួតពិនិត្យលើប្រតិបត្តិការធនធានរ៉ែក្រុមហ៊ុនលោក/លោកស្រី ចាប់ពីថ្ងៃទី......... ខែ................. ឆ្នាំ.............. ដល់ថ្ងៃទី......... ខែ................. ឆ្នាំ..............។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោក លោកស្រី មេត្តាជ្រាបជាព័ត៌មាន និងត្រៀមឯកសារពាក់ព័ន្ធព្រមទាំងចូលរួមសហការក្នុងដំណើរការអធិការកិច្ចរបស់មន្ត្រីអធិការកិច្ចធនធានរ៉ែមានសមត្ថកិច្ច តាមកាលបរិច្ឆេទកំណត់ខាងលើជាចាំបាច់។

....................... ថ្ងៃទី........... ខែ.................. ឆ្នាំ..................

**ប្រធាន**

ឧបសម្ព័ន្ធទី២ នៃសេចក្តីពន្យល់អំពីគោលបំណងនៃការធ្វើអធិការកិច្ច
នៃប្រកាសស្តីពីបែបបទនិងនីតិវិធីនៃការធ្វើអធិការកិច្ចធនធានរ៉ែ សម្រាប់ការធ្វើអាជីវកម្មខ្សាច់ ក្រួស ឡាតេរីត ខ្សាច់បក និងអាចម៍ដី

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF MINES AND ENERGY

**ក្រុមការងារត្រួតពិនិត្យនិង**
**ធ្វើអធិការកិច្ច ក្រុមទី**........./
**មន្ទីររ៉ែនិងថាមពល**..................................

## សេចក្តីពន្យល់អំពីគោលបំណងនៃការធ្វើអធិការកិច្ចធនធានរ៉ែ

យើងខ្ញុំ ក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ចនៃក្រសួងរ៉ែនិងថាមពល សូមជម្រាបលោក លោកស្រី ម្ចាស់ការដ្ឋានឬអ្នកតំណាងឬអ្នកទទួលខុសត្រូវជ្រាបថាៈ ក្រុមការងារយើងខ្ញុំចុះត្រួតពិនិត្យលើអនុលោមភាពតាមលក្ខណៈបច្ចេកទេស លក្ខខណ្ឌអាជ្ញាបណ្ណ ការណែនាំផ្សេងៗរបស់ក្រសួងរ៉ែ និងថាមពល ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

ព័ត៌មានដែលលោក លោកស្រីបានផ្តល់នឹងត្រូវដាក់បញ្ចូលទៅក្នុងកំណត់ហេតុស្តីពីការត្រួតពិនិត្យនិងធ្វើអធិការកិច្ចធនធានរ៉ែ ហេតុនេះហើយ លោក លោកស្រីត្រូវធានាបានថារាល់ព័ត៌មានដែលផ្តល់ឱ្យក្រុមការងារយើងខ្ញុំគឺជាព័ត៌មានពិតប្រាកដមែន។ ក្នុងករណីក្រុមការងារយើងខ្ញុំរកឃើញថាព័ត៌មានដែលត្រូវបានផ្តល់ឱ្យមិនត្រឹមត្រូវ និង/ឬប្រកបដោយចេតនាមិនស្មោះត្រង់ ក្រុមការងារនឹងចាត់វិធានការតាមនីតិវិធីច្បាប់ទៅលើរាល់សិទ្ធិនៃប្រតិបត្តិការធនធានរ៉ែរបស់លោក លោកស្រី ដែលបានទទួលស្របតាមប្រកាសស្តីពីលក្ខខណ្ឌអាជ្ញាបណ្ណធនធានរ៉ែ។

ក្រុមការងារយើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា លោក លោកស្រី ជ្រាបនិងផ្តល់កិច្ចសហការផ្សេងៗដែលចាំបាច់របស់ក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ចធនធានរ៉ែ ព្រមទាំងបង្កលក្ខណៈងាយស្រួលដល់ដំណើរការធ្វើអធិការកិច្ចឱ្យប្រព្រឹត្តទៅដោយរលូននិងល្អប្រសើរ។

**ឧបសម្ព័ន្ធទី៣(ក) ស្តីពី "កំណត់ហេតុស្តីពីការចុះត្រួតពិនិត្យនិងធ្វើអធិការកិច្ចធនធានរ៉ែ" នៃ ប្រកាសស្តីពីបែបបទនិងនីតិវិធីនៃការធ្វើអធិការកិច្ចធនធានរ៉ែ សម្រាប់ការធ្វើអាជីវកម្មខ្សាច់ ក្រួស ឡាតេរីត ខ្សាច់បក និងអាចម៍ដី**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងរ៉ែ និងថាមពល
MINISTRY OF MINES AND ENERGY

**ក្រុមការងារត្រួតពិនិត្យនិង**
**ធ្វើអធិការកិច្ច ក្រុមទី........./**
**មន្ទីររ៉ែនិងថាមពល.................................**

# កំណត់ហេតុ
## ស្តីពី
## ការចុះត្រួតពិនិត្យនិងធ្វើអធិការកិច្ចធនធានរ៉ែ

..............................................................................................................................................

**ដែលមានទីតាំងស្ថិតនៅ**..............................................................................................................

..............................................................................................................................................

**និយាមការ** X: ................................ Y: ................................ (ប្រព័ន្ធ ..................................)

**ប្រកាសស្តីពីលក្ខខណ្ឌអាជ្ញាបណ្ណធនធានរ៉ែ**...........................................................................

..............................................................................................................................................

**លេខ**................................ **ចុះថ្ងៃទី**.......... **ខែ**.............. **ឆ្នាំ**................

ឆ្នាំពីរពាន់....................... ខែ.................. ថ្ងៃទី....................... វេលាម៉ោង..............................
ក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ច ដឹកនាំដោយ.......................................................................
.........................................និងមានការសហការពី .................................................................................
..............................................................................................................................................
និងចូលរួមដោយក្រុមការងារដែលមានសមាសភាពដូចខាងក្រោម៖

១- លោក.......................................................... ឋាន:...................................................
២- លោក.......................................................... ឋាន:...................................................
៣- លោក.......................................................... ឋាន:...................................................
៤- លោក.......................................................... ឋាន:...................................................
៥- លោក.......................................................... ឋាន:...................................................
៦- លោក.......................................................... ឋាន:...................................................

**ឧបសម្ព័ន្ធទី៣(ក) ស្ដីពី "កំណត់ហេតុស្ដីពីការចុះត្រួតពិនិត្យនិងធ្វើអធិការកិច្ចធនធានរ៉ែ" នៃ ប្រកាសស្ដីពីបែបបទនិងនីតិវិធីនៃការធ្វើអធិការកិច្ចធនធានរ៉ែ សម្រាប់ការធ្វើអាជីវកម្មខ្សាច់ ក្រួស ឡាតេរីត ខ្សាច់មក និងអាចម៍ដី**

ការធ្វើអធិការកិច្ចធនធានរ៉ែនៅទីតាំងខាងលើនេះ ត្រូវបានធ្វើឡើងដោយមានការចូលរួមសហការពីភាគីម្ចាស់ការដ្ឋាន/អ្នកតំណាង/អ្នកទទួលខុសត្រូវដែលមានសមាសភាពដូចខាងក្រោមៈ

១- ឈ្មោះ.................................................. ភេទ............. កាន់អត្តសញ្ញាណបណ្ណ/លិខិតឆ្លងដែនលេខ ............................................................ ចុះថ្ងៃទី.................................. ជា............................ នៃទីតាំងការដ្ឋានខាងលើ។

២- ឈ្មោះ.................................................. ភេទ............. កាន់អត្តសញ្ញាណបណ្ណ/លិខិតឆ្លងដែនលេខ ............................................................ ចុះថ្ងៃទី.................................. ជា............................ នៃទីតាំងការដ្ឋានខាងលើ។

៣- ឈ្មោះ.................................................. ភេទ............. កាន់អត្តសញ្ញាណបណ្ណ/លិខិតឆ្លងដែនលេខ ............................................................ ចុះថ្ងៃទី.................................. ជា............................ នៃទីតាំងការដ្ឋានខាងលើ។

ក្រោយពីបានធ្វើអធិការកិច្ចក្នុងទីតាំងប្រតិបត្តិការធនធានរ៉ែខាងលើរួចមក ក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ច បានរកឃើញថា ៖..........................................................................................................
.........................................................................................................................................
.........................................................................................................................................
.........................................................................................................................................
.........................................................................................................................................
.........................................................................................................................................
.........................................................................................................................................
.........................................................................................................................................
.........................................................................................................................................
.........................................................................................................................................
.........................................................................................................................................
.........................................................................................................................................
.........................................................................................................................................
.........................................................................................................................................
.........................................................................................................................................
.........................................................................................................................................

**ឧបសម្ព័ន្ធទី៣(ក) ស្តីពី "កំណត់ហេតុស្តីពីការចុះត្រួតពិនិត្យនិងធ្វើអធិការកិច្ចធនធានរ៉ែ" នៃ ប្រកាសស្តីពីបែបបទនិងនីតិវិធីនៃការធ្វើអធិការកិច្ចធនធានរ៉ែ សម្រាប់ការធ្វើអាជីវកម្មខ្សាច់ ក្រួស ឡាតេរីត ខ្សាច់បក និងអាចម៍ដី**

...........................................................................................................................
...........................................................................................................................
...........................................................................................................................
...........................................................................................................................
...........................................................................................................................
...........................................................................................................................
...........................................................................................................................
...........................................................................................................................
...........................................................................................................................
...........................................................................................................................
...........................................................................................................................
...........................................................................................................................
...........................................................................................................................
...........................................................................................................................
...........................................................................................................................
...........................................................................................................................
...........................................................................................................................
...........................................................................................................................
...........................................................................................................................
...........................................................................................................................
...........................................................................................................................
...........................................................................................................................
...........................................................................................................................
...........................................................................................................................
...........................................................................................................................
...........................................................................................................................
...........................................................................................................................

**ឧបសម្ព័ន្ធទី៣(ក) ស្តីពី "កំណត់ហេតុស្តីពីការចុះត្រួតពិនិត្យនិងធ្វើអធិការកិច្ចធនធានរ៉ែ" នៃ ប្រកាសស្តីពីបែបបទនិងនីតិវិធីនៃការធ្វើអធិការកិច្ចធនធានរ៉ែ សម្រាប់ការធ្វើអាជីវកម្មខ្សាច់ ក្រួស ឡាតេរីត ខ្សាច់បក និងអាចម៍ដី**

ដូចនេះហើយក្រុមការងារបានសម្រេចដាក់ចេញនូវវិធានការមួយចំនួនដូចមានកំណត់ក្នុង៖

- ☐ លិខិតកែតម្រូវ/ ☐លិខិតព្រមាន ចុះថ្ងៃទី.................... ខែ..................... ឆ្នាំ.................... ចេញដោយក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ច ក្រុមទី............./ មន្ទីររ៉ែនិងថាមពល...........................។
- ☐ សេចក្តីសម្រេចផ្អាកផ្នែកណាមួយឬទាំងស្រុងជាបណ្តោះអាសន្ន ចុះថ្ងៃទី.................. ខែ..................... ឆ្នាំ.................... ចេញដោយក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ច ក្រុមទី............./ មន្ទីររ៉ែនិងថាមពល........................... ។
- ☐ សេចក្តីជូនដំណឹងស្តីពីការឃាត់ទុកវត្ថុតាង ចុះថ្ងៃទី.................... ខែ..................... ឆ្នាំ.................... ចេញដោយក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ច ក្រុមទី............/ មន្ទីររ៉ែនិងថាមពល........................។

កំណត់ហេតុបានបញ្ចប់នៅវេលាម៉ោង.................................................... នាថ្ងៃខែឆ្នាំដដែល។

- ☐ យើងបានអានឱ្យស្តាប់ ឬបានឱ្យភាគីម្ចាស់ការដ្ឋាន/អ្នកតំណាង/អ្នកទទួលខុសត្រូវអានឡើងវិញនូវខ្លឹមសារនៃកំណត់ហេតុទាំងអស់ខាងលើ ហើយភាគីម្ចាស់ការដ្ឋាន/អ្នកតំណាង/អ្នកទទួលខុសត្រូវបានឯកភាពចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃ លើកំណត់ហេតុនេះ។
- ☐ យើងបានអានឱ្យស្តាប់ ឬបានឱ្យភាគីម្ចាស់ការដ្ឋាន/អ្នកតំណាង/អ្នកទទួលខុសត្រូវអានឡើងវិញនូវខ្លឹមសារនៃកំណត់ហេតុទាំងអស់ខាងលើហើយភាគីម្ចាស់ការដ្ឋាន/អ្នកតំណាង/អ្នកទទួលខុសត្រូវពុំបានឯកភាពចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃ លើកំណត់ហេតុនេះទេ។

| បានឃើញនិងឯកភាព | ស្នាមមេដៃ/ហត្ថលេខា | |
|---|---|---|
| **ប្រធានក្រុមការងារ** | **ម្ចាស់ការដ្ឋាន/តំណាងម្ចាស់ការដ្ឋាន** | **អ្នកធ្វើកំណត់ហេតុ** |

**សមាសភាពក្រុមការងារ**

១- ..........................................
២- ..........................................
៣- ..........................................
៤- ..........................................
៥- ..........................................
៦- ..........................................
៧- ..........................................
៨- ..........................................
៩- ..........................................
១០- ..........................................

**ឧបសម្ព័ន្ធទី៣(ខ) ស្តីពី "លិខិតឱ្យកែតម្រូវ" នៃ**
**ប្រកាសស្តីពីបែបបទនិងនីតិវិធីនៃការធ្វើអធិការកិច្ចធនធានរ៉ែ សម្រាប់ការធ្វើអាជីវកម្មខ្សាច់ ក្រួស ឡាតេរីត ខ្សាច់បក និងអាចម៍ដី**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមការងារត្រួតពិនិត្យនិង**
**ធ្វើអធិការកិច្ច ក្រុមទី........./**
**មន្ទីររ៉ែនិងថាមពល..................................**

# លិខិតឱ្យកែតម្រូវ

## ក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ចក្រុមទី......../
## មន្ទីររ៉ែនិងថាមពល..................................

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៩ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២៣ មាត្រា៣០ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ និងមាត្រា៤០ នៃច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញប្រកាសលេខ..................ប្រក. ចុះថ្ងៃទី......... ខែ............. ឆ្នាំ.................... ស្តីពីបែបបទនិងនីតិវិធីនៃការធ្វើអធិការកិច្ចធនធានរ៉ែ សម្រាប់ការធ្វើអាជីវកម្មខ្សាច់ ក្រួស ឡាតេរីត ខ្សាច់បក និងអាចម៍ដី
- ប្រកាសលេខ............................. ចុះថ្ងៃទី............. ខែ.............. ឆ្នាំ.................. ស្តីពីលក្ខខណ្ឌនៃអាជ្ញាបណ្ណ ...........................................................................................................................
- កំណត់ហេតុស្តីពីការត្រួតពិនិត្យនិងធ្វើអធិការកិច្ច........................................................................ ...........................................................................................................................

## សម្រេច

ឱ្យក្រុមហ៊ុន/សហគ្រាស/ឈ្មោះ..........................................................................................
ធ្វើការកែតម្រូវ ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ បទប្បញ្ញត្តិពាក់ព័ន្ធ និងលក្ខខណ្ឌអាជ្ញាបណ្ណ ដូចខាងក្រោម៖

១- ...................................................................................................................
...........................................................................................................................

មូលហេតុ..............................................................................................................
...........................................................................................................................
...........................................................................................................................

ទំព័រ......... នៃ.........

**ឧបសម្ព័ន្ធទី៣(ខ) ស្តីពី "លិខិតឱ្យកែតម្រូវ" នៃ**
**ប្រកាសស្តីពីបែបបទនិងនីតិវិធីនៃការធ្វើអធិការកិច្ចធនធានរ៉ែ សម្រាប់ការធ្វើអាជីវកម្មខ្សាច់ ក្រួស ឡាតេរីត ខ្សាច់បក និងអាចម៍ដី**

ក្រុមហ៊ុន/សហគ្រាស/ឈ្មោះ.................................................................... ត្រូវកែតម្រូវកំហុសខាងលើ ចាប់ពីថ្ងៃទី.......... ខែ................... ឆ្នាំ.................. ។

ក្នុងករណីសាមីខ្លួនមិនព្រមកែតម្រូវតាមពេលវេលាខាងលើ ក្រសួងរ៉ែនិងថាមពល នឹងអនុវត្តវិធានការច្បាប់តាមនីតិវិធី ។

....................... ថ្ងៃទី........... ខែ............ឆ្នាំ............

**ប្រធាន**

**ឧបសម្ព័ន្ធទី៣(គ) ស្តីពី "លិខិតព្រមាន" នៃ**
**ប្រកាសស្តីពីបែបបទនិងនីតិវិធីនៃការធ្វើអធិការកិច្ចធនធានរ៉ែ សម្រាប់ការធ្វើអាជីវកម្មខ្សាច់ ក្រួស ឡាតេរីត ខ្សាច់បក និងអាចម៍ដី**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមការងារត្រួតពិនិត្យនិង**
**ធ្វើអធិការកិច្ច ក្រុមទី........./**
**មន្ទីររ៉ែនិងថាមពល...................................**

## លិខិតព្រមាន

**ក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ចក្រុមទី......../**
**មន្ទីររ៉ែនិងថាមពល..................................**

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៩ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២៣ មាត្រា៣០ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ និងមាត្រា៤០ នៃច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញប្រកាសលេខ..................ប្រក. ចុះថ្ងៃទី......... ខែ............. ឆ្នាំ.................... ស្តីពីបែបបទនិងនីតិវិធីនៃការធ្វើអធិការកិច្ចធនធានរ៉ែ សម្រាប់ការធ្វើអាជីវកម្មខ្សាច់ ក្រួស ឡាតេរីត ខ្សាច់បក និងអាចម៍ដី
- ប្រកាសស្តីពីលក្ខខណ្ឌនៃអាជ្ញាបណ្ណលេខ................................. ចុះថ្ងៃទី.......... ខែ.............. ឆ្នាំ................. របស់ក្រសួងរ៉ែនិងថាមពល
- កំណត់ហេតុស្តីពីការត្រួតពិនិត្យនិងធ្វើអធិការកិច្ច.......................................................................................
.................................................................................................................................

## សម្រេច

ឱ្យក្រុមហ៊ុន/សហគ្រាស/ឈ្មោះ............................................................................................ ដែលបានប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ បទប្បញ្ញត្តិពាក់ព័ន្ធ និងលក្ខខណ្ឌអាជ្ញាបណ្ណ ដូចខាងក្រោម៖

១- .................................................................................................................................
.................................................................................................................................

មូលហេតុ.................................................................................................................
.................................................................................................................................
.................................................................................................................................

**ឧបសម្ព័ន្ធទី៣(គ) ស្តីពី "លិខិតព្រមាន" នៃ**
**ប្រកាសស្តីពីបែបបទនិងនីតិវិធីនៃការធ្វើអធិការកិច្ចធនធានរ៉ែ សម្រាប់ការធ្វើអាជីវកម្មខ្សាច់ ក្រួស ឡាតេរីត ខ្សាច់បក និងអាចម៍ដី**

ក្រុមហ៊ុន/សហគ្រាស/ឈ្មោះ........................................................................ ត្រូវបញ្ឈប់អំពើល្មើសដែលបានប្រព្រឹត្ត និងត្រូវអនុវត្តតាមច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ បទប្បញ្ញត្តិពាក់ព័ន្ធ និងលក្ខខណ្ឌអាជ្ញាបណ្ណ ចាប់ពីថ្ងៃទី.......... ខែ.................... ឆ្នាំ.................. ។

ក្នុងករណីសាមីខ្លួន មិនព្រមកែតម្រូវអំពើល្មើស តាមពេលវេលាកំណត់ខាងលើ ក្រសួងរ៉ែ និងថាមពលនឹងអនុវត្តវិធានការតាមនីតិវិធីច្បាប់ជាធរមាន។

....................... ថ្ងៃទី.......... ខែ............ឆ្នាំ............

**ប្រធាន**

**ឧបសម្ព័ន្ធទី៤ស្ដីពី "សេចក្ដីសម្រេចស្ដីពីការផ្អាកផ្នែកណាមួយឬទាំងស្រុងជាបណ្ដោះអាសន្ន" នៃប្រកាសស្ដីពីបែបបទនិងនីតិវិធីនៃការធ្វើអធិការកិច្ចធនធានរ៉ែ សម្រាប់ការធ្វើអាជីវកម្មខ្សាច់ ក្រួស ឡាតេរីត ខ្សាច់បក និងអាចម៍ដី**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ច ក្រុមទី........./**
**មន្ទីររ៉ែនិងថាមពល..................................**

# សេចក្ដីសម្រេច
# ស្ដីពី
# ការផ្អាកផ្នែកណាមួយឬទាំងស្រុងជាបណ្ដោះអាសន្ន

## ក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ចក្រុមទី......../
## មន្ទីររ៉ែនិងថាមពល..................................

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៩ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យច្បាប់ស្ដីពីវិសោធនកម្មមាត្រា៣ មាត្រា២៣ មាត្រា៣០ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ និងមាត្រា៤០ នៃច្បាប់ស្ដីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញប្រកាសលេខ..................ប្រក. ចុះថ្ងៃទី......... ខែ............. ឆ្នាំ.................... ស្ដីពីបែបបទនិងនីតិវិធីនៃការធ្វើអធិការកិច្ចធនធានរ៉ែ សម្រាប់ការធ្វើអាជីវកម្មខ្សាច់ ក្រួស ឡាតេរីត ខ្សាច់បក និងអាចម៍ដី
- កំណត់ហេតុស្ដីពីការត្រួតពិនិត្យនិងធ្វើអធិការកិច្ច.............................................................................................. ..
.........................................................................................................................................................

# សម្រេច

ផ្អាកប្រតិបត្តិការធនធានរ៉ែ ☐មួយផ្នែក ☐ទាំងស្រុង នៃប្រកាសលេខ............................................................ ចុះថ្ងៃទី......... ខែ............... ឆ្នាំ................ ស្ដីពីលក្ខខណ្ឌអាជ្ញាបណ្ណ.................................................... ..............................................................................................................................................................។

ប្រតិបត្តិការធនធានរ៉ែដែលត្រូវផ្អាកមាន ដូចខាងក្រោម៖

១- ..................................................................................................................................
..................................................................................................................................................
..................................................................................................................................................
..................................................................................................................................................

**ឧបសម្ព័ន្ធទី៤ស្តីពី "សេចក្តីសម្រេចស្តីពីការផ្អាកផ្នែកណាមួយឬទាំងស្រុងជាបណ្តោះអាសន្ន" នៃប្រកាសស្តីពីបែបបទនិងនីតិវិធីនៃការធ្វើអធិការកិច្ចធនធានរ៉ែ សម្រាប់ការធ្វើអាជីវកម្មខ្សាច់ ក្រួស ឡាតេរីត ខ្សាច់បក និងអាចម៍ដី**

ក្រុមហ៊ុន/សហគ្រាស/ឈ្មោះ.............................................ខាងលើ ត្រូវផ្អាកសកម្មភាពប្រតិបត្តិការធនធានរ៉ែខាងលើ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេច រហូតដល់ថ្ងៃទី......... ខែ............ ឆ្នាំ............។

ក្នុងករណីក្រុមហ៊ុននៅតែបន្តសកម្មភាពប្រតិបត្តិការធនធានរ៉ែទៀត ក្រសួងរ៉ែនិងថាមពលនឹងអនុវត្តវិធានការតាមនីតិវិធីច្បាប់ជាធរមាន។

......................... ថ្ងៃទី........... ខែ................ ឆ្នាំ......................

**ប្រធាន**

**ឧបសម្ព័ន្ធទី៥ "គំរូសេចក្ដីជូនដំណឹងស្ដីពីការឃាត់ទុកវត្ថុតាង" នៃប្រកាសស្ដីពីបែបបទនិងនីតិវិធីនៃការធ្វើអធិការកិច្ចធនធានរ៉ែ សម្រាប់ការធ្វើអាជីវកម្មខ្សាច់ គ្រួស ឡាតេរីត ខ្សាច់បក និងអាចម៍ដី**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមការងារត្រួតពិនិត្យនិង**
**ធ្វើអធិការកិច្ច ក្រុមទី**........./
**មន្ទីររ៉ែនិងថាមពល**.................................

# សេចក្ដីជូនដំណឹងស្ដីពីការឃាត់ទុកវត្ថុតាង

សូមជូនដំណឹងដល់លោក-លោកស្រីដែលជាម្ចាស់សម្ភារៈដែលត្រូវបានឃាត់ទុក មេត្តាជ្រាបថា ក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ចនៃក្រសួងរ៉ែនិងថាមពល ក្រុមទី............ /មន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត..................... បានឃាត់ទុក វត្ថុតាងឬភស្តុតាងនៃបទល្មើសដែលពាក់ព័ន្ធនឹងប្រតិបត្តិការធនធានរ៉ែរួមមាន៖

១- ..........................................................................................................
..........................................................................................................
២- ..........................................................................................................
..........................................................................................................
៣- ..........................................................................................................
..........................................................................................................
៤- ..........................................................................................................
..........................................................................................................
៥- ..........................................................................................................
..........................................................................................................
៦- ..........................................................................................................
..........................................................................................................
៧- ..........................................................................................................
..........................................................................................................
៨- ..........................................................................................................
..........................................................................................................
៩- ..........................................................................................................
..........................................................................................................
១០- ..........................................................................................................
..........................................................................................................
១១- ..........................................................................................................
..........................................................................................................

**ឧបសម្ព័ន្ធទី៥ "គំរូសេចក្តីជូនដំណឹងស្តីពីការឃាត់ទុកវត្ថុតាង" នៃប្រកាសស្តីពីបែបបទនិងនីតិវិធីនៃការធ្វើអធិការកិច្ចធនធានរ៉ែ សម្រាប់ការធ្វើអាជីវកម្មខ្សាច់ ក្រួស ឡាតេរីត ខ្សាច់បក និងអាចម៍ដី**

សូមម្ចាស់សម្ភារៈឬវត្ថុតាង ចូលខ្លួនមកដោះស្រាយនៅ.......................................................................

.................................................................................................................................................

ចាប់ពីថ្ងៃទី............... ខែ............... ឆ្នាំ........................ដល់ថ្ងៃទី................ ខែ.............. ឆ្នាំ.......................

ពុំដូចនោះទេ សម្ភារៈដែលត្រូវបានឃាត់ទុកនឹងត្រូវរឹបអូសជាសម្បត្តិរដ្ឋ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោក លោកស្រី ម្ចាស់ការដ្ឋាន ឬ អ្នកតំណាង ជ្រាបជាព័ត៌មាន និងចូលខ្លួនដើម្បីមកដោះស្រាយបញ្ហាពាក់ព័ន្ធខាងលើឱ្យបានទាន់ពេលវេលា។

................................ថ្ងៃទី..........ខែ................ឆ្នាំ................

**ប្រធាន**